## ការប្រព្រឹត្តទៅរបស់ គ.ជ.គ.

**មាត្រា៤ .-**

**គ.ជ.គ.** ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិច១(មួយ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ **គ.ជ.គ.** អាចប្រជុំជាវិសាមញ្ញបាន។

ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីអវត្តមាន សមាជិក **គ.ជ.គ.** ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចចូលរួមប្រជុំជំនួស។

ប្រធាន **គ.ជ.គ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឥស្សរជន ដៃគូអភិវឌ្ឍវិស័យឯកជន អ្នកជំនាញការជាតិ អន្តរជាតិ ដើម្បីចូលរួមផ្តល់យោបល់ក្នុងករណីចាំបាច់។

បែបបទនិងនីតិវិធីការងារ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.គ.**។

**មាត្រា៥ .-**

**គ.ជ.គ.** មានគណៈកម្មាធិការជាតិភស្តុភារកម្ម ដែលសរសេរជាអក្សរកាត់ថា **គ.ជ.គ.** ជាអង្គភាពប្រតិបត្តិ ដើម្បីគ្រប់គ្រង សម្របសម្រួល ប្រតិបត្តិ និងអភិវឌ្ឍវិស័យភស្តុភារកម្ម ដែលមានសមាសភាព ដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ប្រធាន
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប អនុប្រធាន
- អគ្គលេខាធិការនៃគណៈកម្មាធិការវិនិយោគកម្ពុជា អនុប្រធាន
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងផែនការ១រូប សមាជិក



- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងបរិស្ថាន១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល១រូប សមាជិក
- អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
- អគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ១រូប សមាជិក
- អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា១រូប សមាជិក
- អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា១រូប សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានកាំកុងត្រូល សមាជិក
- អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សមាជិក
- អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ សមាជិក
- អគ្គនាយកភ្នាក់ងារកម្ពុជានាវាចរ (កាំសាប) សមាជិក
- ប្រធានសភាពាណិជ្ជកម្មកម្ពុជា សមាជិក
- តំណាងគ្រឹះស្ថានឧត្តមសិក្សាដែលពាក់ព័ន្ធវិស័យភស្តុភារកម្ម សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្មក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិកអចិន្ត្រៃយ៍។

**គ.ជ.គ**. អាចមានសមាសភាពបន្ថែម តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ**គ.ជ.គ**. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៦ ._**

**គ.ជ.ភ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំរៀបចំបង្កើតនូវឯកសារគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការគ្រប់គ្រង ប្រតិបត្តិ និងអភិវឌ្ឍវិស័យភស្តុភារកម្មនៃព្រះរាជាណាចក្រកម្ពុជា ដោយធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីដាក់ជូន **គ.ជ.ភ.** ពិនិត្យនិងសម្រេច
- សម្របសម្រួលនិងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តរបស់វិស័យភស្តុភារកម្ម ឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាព
- ជំរុញការអនុវត្តផែនការនានាដែលទាក់ទងនឹងវិស័យភស្តុភារកម្មអន្តរជាតិក្នុងក្របខ័ណ្ឌអាស៊ាននិងពិភពលោក
- ពិនិត្យនិងលើកសំណើកែសម្រួលឬធ្វើវិសោធនកម្មបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិស័យភស្តុភារកម្ម ឲ្យមានសង្គតិភាពទៅនឹងលិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាន
- ស្វែងរកធនធានហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ប្រតិបត្តិ ទ្រទ្រង់ និងលើកកម្ពស់ជំរុញការអភិវឌ្ឍវិស័យភស្តុភារកម្ម
- រៀបចំទិន្នន័យគោលនិងសូចនាករសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់បណ្តាក្រសួង ស្ថាប័ន និងវិស័យឯកជនដែលមានចែងក្នុងផែនការមេភស្តុភារកម្ម
- ធ្វើរបាយការណ៍សកម្មភាពការងារជូន **គ.ជ.ភ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ភ.** ប្រគល់ជូន។

**មាត្រា៧ ._**

**គ.ជ.ភ.** ត្រូវបង្កើតក្រុមការងារបង្គោលតាមក្រសួង ស្ថាប័ន និងវិស័យឯកជន រៀងៗខ្លួន ដើម្បីសហការជាមួយលេខាធិការដ្ឋានរបស់ **គ.ជ.ភ.**។

**មាត្រា៨ ._**

**គ.ជ.ភ.** ត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ **គ.ជ.ភ.** អាចប្រជុំជាវិសាមញ្ញបាន។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ក្នុងករណីអវត្តមាន សមាជិក **គ.ជ.ត.** ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេច ចូលរួមប្រជុំជំនួស។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការប្រជុំតាមការប្រគល់សិទ្ធិពីប្រធាន។

ប្រធាន **គ.ជ.ត.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ឥស្សរជន ដៃគូអភិវឌ្ឍ វិស័យឯកជន អ្នកជំនាញការជាតិ អន្តរជាតិ ដើម្បីចូលរួមផ្តល់យោបល់ ក្នុងករណីចាំបាច់។

បែបបទនិងនីតិវិធីការងារត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ត.** ។

**មាត្រា៩ ._**

**គ.ជ.ត.** មានសិទ្ធិបង្កើតក្រុមការងារនិងក្រុមពិគ្រោះយោបល់ ដើម្បីជួយបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

សមាសភាពនិងតួនាទីភារកិច្ចរបស់ក្រុមការងារនិងក្រុមពិគ្រោះយោបល់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ត.**។

**មាត្រា១០ ._**

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការ និងមានភារកិច្ចផ្តល់ឯកសារព័ត៌មានពាក់ព័ន្ធនានាជូនដល់ **គ.ជ.ត.** ។

**មាត្រា១១ ._**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានអគ្គនាយកដ្ឋានភស្តុភារកម្ម ជាលេខាធិការដ្ឋាន **គ.ជ.ត.** ដែលមានតួនាទីនិងភារកិច្ចបន្ថែមដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពការងារនិងគម្រោងថវិការបស់លេខាធិការដ្ឋាន
- បំពេញការងាររដ្ឋបាលនិងហិរញ្ញវត្ថុជូន **គ.ជ.ត.**
- ប្រមូលចងក្រងឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្តនានា ដែលទាក់ទងនឹងវិស័យភស្តុភារកម្ម
- ដឹកនាំនិងសហការជាមួយក្រុមការងារឬមន្ត្រីបង្គោលរបស់ក្រសួង ស្ថាប័នដែលមានសមាសភាពក្នុង **គ.ជ.ត.** និងភាគីពាក់ព័ន្ធនានា ដើម្បីជួយរៀបចំ តាមដាន ការអនុវត្ត និងអភិវឌ្ឍ៖
  - ក- ផែនការមេ យុទ្ធសាស្ត្រ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារភស្តុភារកម្ម។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ខ- ផែនការបណ្តុះបណ្តាលធនធានមនុស្សនិងផ្សព្វផ្សាយព័ត៌មានក្នុងវិស័យភស្តុភារកម្ម។

គ- ផែនការផ្គត់ផ្គង់ធនធានចាំបាច់នានា សម្រាប់ដំណើរការការងារក្នុងវិស័យភស្តុភារកម្ម។

ឃ- ស្រាវជ្រាវនិងអភិវឌ្ឍវិស័យភស្តុភារកម្ម។

ង- ផែនការធ្វើសមាហរណកម្មប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាភស្តុភារកម្ម។

ច- ផែនការលើកកម្ពស់និងគាំទ្រដល់វិស័យឧស្សាហកម្មភស្តុភារកម្មជាតិ។

ឆ- ផែនការធានាសុវត្ថិភាពក្នុងចង្វាក់ផ្គត់ផ្គង់នៃវិស័យភស្តុភារកម្ម។

ជ- នវានុវត្តភាពក្នុងវិស័យភស្តុភារកម្ម។

- ពិនិត្យ វាយតម្លៃអំពីសង្គតិភាពនិងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យភស្តុភារកម្ម និងលើកសំណើផ្សេងៗដាក់ជូន **គ.ជ.ភ.** ដើម្បី ពិនិត្យសម្រេច
- ធ្វើរបាយការណ៍សកម្មភាពការងារ កំណត់ហេតុកិច្ចប្រជុំរបស់ **ក.ជ.ភ.**និង**គ.ជ.ភ.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ភ.** ប្រគល់ជូន។

**មាត្រា១២ ._**

**ក.ជ.ភ.** មានសិទ្ធិប្រើត្រារបស់ក្រសួងសាធារណការនិងដឹកជញ្ជូន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១៣ ._**

**ក.ជ.ភ.** មានថវិកាដោយឡែករបស់ខ្លួន ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**ក.ជ.ភ.** មានសិទ្ធិទទួលនិងចាត់ចែង ប្រើតាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៤ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១៥ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/១១១៧/១១១០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**
**ហត្ថលេខា**
**ស៊ុន ចាន់ថុល**

លេខ: ១០៩៧/ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/១០៩៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ និងថ្នាក់ ជាករណីពិសេស ដល់ ឯកឧត្តម **សាយ ស៊ីថា** ពីឋានន្តរស័ក្តិ វរមន្ត្រីថ្នាក់លេខ២ មកឧត្តមមន្ត្រីថ្នាក់លេខ ៦ ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : តែងតាំងមុខតំណែងមន្ត្រីរាជការ ០២រូប ជាអនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ មានឋានៈស្មើ**អគ្គនាយក** ៖

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ស៊ុន ហួរ** អត្តលេខ ៧៨១១១
២-ឯកឧត្តម **សាយ ស៊ីថា** ឋានន្តរស័ក្តិ ឧត្តមមន្ត្រីថ្នាក់លេខ ៦

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ករក. ១៧១១. ១១១១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

លេខៈ ១១០៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/ ១០៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងនិងផ្តល់ឋានៈដល់មន្ត្រីរាជការ០២រូប ជាទីប្រឹក្សាអមក្រសួងមុខងារសាធារណៈ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន៖

១- ឯកឧត្តម **អ៊ុក សុភាព** ជាទីប្រឹក្សាអមក្រសួង មានឋានៈស្មើអនុរដ្ឋលេខាធិការ

២- លោកជំទាវ **ឆាយ គឹមសុទ្ធី** ជាទីប្រឹក្សាអមក្រសួង មានឋានៈស្មើអនុរដ្ឋលេខាធិការ

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ១០៩៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៧៧.១៧/១១.១១៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៧*

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/១០៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ជីម រដ្ឋា** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៧១១. ១១១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧

លេខ: ១១២៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/១០៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូន ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រី ដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ចាន់ ហេង** ជាទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

លេខ: ១១២១ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/ ១០៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោកស្រី **ឆាច សុផានី** ពីឋានន្តរសក្តិឧត្តមអគ្គានុរក្សពន្ធនាគារ ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ មកឋានន្តរសក្តិ **ឧត្តមសេនីយ៍ត្រី** អត្តលេខ ៧៨៣៨៤ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៧១១.១១១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

លេខ: ១១២៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/ ១០៦៩

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **គីម សៀកចលនា** ពីឋានន្តរសក្ដិវរអគិបាលថ្នាក់លេខ៣ ក្របខ័ណ្ឌអគិបាល នៃមន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មកឋានន្តរសក្ដិ **ឧត្ដមសេនីយ៍ត្រី** អត្តលេខ ៧៩១៤៧ នាយនគរបាលថ្នាក់ឧត្ដមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៧៧.១៧១១.១១១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

លេខ: ១១២៤ ស.ណ
**សំណៅដែលមានអត្ថន័យជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/ ១០៧៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ដល់លោកឧត្តមសេនីយ៍ត្រី **សុខ រស្មី** អត្តលេខ ០៥៤៧៤ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧. ១៧/១១. ១១១៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

លេខៈ ១១២៦ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/១១០០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់លោកវរសេនីយ៍ឯក **អ៊ឹង ថា** អត្តលេខ ០៧២២៤ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ១១១៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

រាជ. ១៧/១១.១១១៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧

# ព្រះរាជក្រឹត្យ

នស/រកត/១១១៧/ ១១០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**ជូន**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍:**

១-ឯកឧត្តម ហឿន សេងហាក់
២-លោក ឈួរ តារា
៣-លោក កែវ សេដ្ឋា

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា:**

១-លោក ចាន់ ស៊ីណា
២-លោក ឡាយ ចេងលៀង

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា:**

១-ឯកឧត្តម គាម ម៉ារិទ្ធិយ៉ា
២-ឯកឧត្តម ឈឹម ផល
៣-ឯកឧត្តម អ៊ុយ យាង
៤-លោកជំទាវ ខៀវ គីមហ៊ន ឆន់ សារ៉ាត
៥-លោក សុខ សារឿន
៦-លោក សំ សុខុម
៧-លោកស្រី ឆេព សាអ៊ុន
៨-លោកស្រី អ៊ូ ធីតា
៩-លោក រស់ ឈាវិទ្ធ
១០-លោក លន់ ហួរ
១១-លោក សៀង វណ្ណាថារ៉ា
១២-លោក អៀង ជេដ្ឋ
១៣-លោក កែវ ច័ន្ទលី

**ឃ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេនា :**

ឯកឧត្តម លាង ប៊ុនរិទ្ធ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ១១០១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ពរ. ១៧/១១.១១១៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៧*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖ ១៩៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៦ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧
- បានឃើញប្រកាសលេខ ១៥៥៤ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងតាមចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.**_

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ពីជំពូក ៦១ (សេវាកម្ម) ចំនួន ១ ៩០៨ ៥៤៨ ០០០ រៀល និង ពីជំពូក ៦៥ (ឧបត្ថម្ភកធន) ចំនួន ៦៥០ ០០០ ០០០ រៀល មកជំពូក ៦០ (ការទិញ) សរុបចំនួន ២ ៥៥៨ ៥៤៨ ០០០ រៀល (ពីរប៊ីលានប្រាំរយហាសិបប្រាំបីលានប្រាំរយសែសិបប្រាំបីពាន់រៀលគត់) ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

**មាត្រា២.**_

ការបែងចែកឥណទានថវិកាចំណាយផ្ទេក្នុងជំពូកទាំងនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទិញសម្ភារៈការិយាល័យ និងទិញសម្ភារៈបរិក្ខារបច្ចេកទេស ដើម្បីគាំទ្រដល់ការបម្រើការងារអាទិភាពរបស់ក្រសួង។

**មាត្រា៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៩៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់សុខុមាលភាពមនុស្សចាស់ ពង្រឹងគុណភាព និងប្រសិទ្ធភាព នៃការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២._**

អនុក្រឹត្យនេះមានគោលដៅ៖

- គ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់
- ផ្តល់នូវការថែទាំនិងការស្នាក់នៅ
- ផ្តល់នូវតម្រូវការជាមូលដ្ឋានឱ្យមនុស្សចាស់បានរស់នៅជាក្រុម ដោយផ្តោតចំពោះមនុស្សចាស់ដែលក្រីក្រគ្មានទីពឹង ឬគ្មានកូនចៅ ឬគ្មានសាច់ញាតិថែទាំ ឬគ្មានការគាំទ្រពីសហគមន៍។

**មាត្រា៣._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមជ្ឈមណ្ឌលថែទាំមនុស្សចាស់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤._**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- មជ្ឈមណ្ឌល សំដៅដល់ កន្លែងដែលទទួលមនុស្សចាស់ចូលមកស្នាក់នៅ
- គាំពារ សំដៅដល់ ថែទាំ ឬថែរក្សា
- មនុស្សចាស់ សំដៅដល់ មនុស្សដែលមានអាយុចាប់ពី៦០ឆ្នាំឡើង
- លើកកម្ពស់ សំដៅដល់ ស្ទួយឡើង ធ្វើឱ្យខ្ពស់
- សុខុមាលភាព សំដៅដល់ ភាពធ្វើឱ្យប្រសើរឡើងនូវជីវភាព សុខភាព និងផាសុខភាព
- ជនចាស់ជរា សំដៅដល់ មនុស្សដែលមានអាយុចាប់ពី៨០ឆ្នាំឡើង
- ក្រីក្រ សំដៅដល់ គ្មានទ្រព្យសម្បត្តិ គ្មានផ្ទះសំបែង
- គ្រប់គ្រង សំដៅដល់ ថែទាំដោយទទួលរងបន្ទុកមនុស្សចាស់
- គ្មានទីពឹង សំដៅដល់ ទុគត
- សេវាសង្គមកិច្ច សំដៅដល់ ការបម្រើមនុស្សចាស់ទទួលបានការថែទាំឱ្យប្រសើរឡើង
- បទដ្ឋានអប្បរមា សំដៅដល់ លក្ខខណ្ឌដែលទាបបំផុតសម្រាប់ផ្តល់ជូនមនុស្សចាស់
- ក្បួនវេជ្ជសាស្ត្រ សំដៅដល់ ក្បួនពេទ្យសាស្ត្រ
- រូបវន្តបុគ្គល សំដៅដល់ មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល
- នីតិបុគ្គល សំដៅដល់ ក្រុមមនុស្សឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥._**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់ទាំងអស់។

**មាត្រា៦._**

ក្នុងការបង្កើត ដំណើរការអនុវត្ត ការសម្របសម្រួល ការត្រួតពិនិត្យ និងការវាយតម្លៃមជ្ឈមណ្ឌលថែទាំមនុស្សចាស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបង្គាប់នាយកដ្ឋានជំនាញឱ្យបំពេញភារកិច្ចដូចតទៅ៖

- ទទួលពាក្យស្នើសុំបើកមជ្ឈមណ្ឌលថែទាំមនុស្សចាស់
- ចុះធ្វើការប៉ាន់ប្រមាណលក្ខណសម្បត្តិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលរួចធ្វើរបាយការណ៍ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងដើម្បីពិនិត្យនិងសម្រេច
- ចុះកំណត់អត្តសញ្ញាណមជ្ឈមណ្ឌលថែទាំមនុស្សចាស់ទាំងអស់
- ចុះធ្វើអធិការកិច្ចលើការអនុវត្តការថែទាំមនុស្សចាស់
- ផ្តល់ការណែនាំនិងកែលម្អផ្នែកបច្ចេកទេសដល់មជ្ឈមណ្ឌលថែទាំមនុស្សចាស់
- បង្កើតសេវាតាមដាននិងគាំទ្រសម្រាប់មនុស្សចាស់ និងគ្រួសារក្រោយពេលបង្រួបបង្រួម
- ចេញបញ្ជាបិទមជ្ឈមណ្ឌលថែទាំមនុស្សចាស់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

## ជំពូកទី៣
## ការអនុញ្ញាតឱ្យដំណើរការមជ្ឈមណ្ឌលថែទាំមនុស្សចាស់

**មាត្រា៧._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សចាស់ត្រូវដាក់ពាក្យស្នើសុំអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៨._**

លក្ខខណ្ឌនិងទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សចាស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៤
## ភាតព្វកិច្ចរបស់មជ្ឈមណ្ឌលថែទាំមនុស្សចាស់

**មាត្រា៩._**

មជ្ឈមណ្ឌលថែទាំមនុស្សចាស់ទាំងអស់ត្រូវបំពេញកាតព្វកិច្ចនិងលក្ខខណ្ឌនៃការគ្រប់គ្រងមជ្ឈមណ្ឌលនិងការថែទាំមនុស្សចាស់ដែលរស់នៅក្នុងមជ្ឈមណ្ឌល ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៥
## លក្ខខណ្ឌសម្រាប់ទទួលនិងការបញ្ឈប់ឱ្យរស់នៅក្នុងមជ្ឈមណ្ឌល

**មាត្រា១០._**

មនុស្សចាស់ដែលអាចអនុញ្ញាតឱ្យរស់នៅក្នុងមជ្ឈមណ្ឌលថែទាំមនុស្សចាស់បាន ត្រូវមានលក្ខខណ្ឌ

ដូចខាងក្រោម៖

ក. លក្ខណៈមនុស្សចាស់អាចរស់នៅក្នុងមជ្ឈមណ្ឌលថែទាំមនុស្សចាស់របស់រដ្ឋ ៖

- ជាមនុស្សចាស់ក្រីក្រដែលគ្មានកូនចៅ ឬសាច់ញាតិជួយមើលថែទាំ
- ជាមនុស្សចាស់បែកចេញពីគ្រួសារ ដោយត្រូវកូនចៅបោះបង់ចោល ឬកូនចៅជាប់ពន្ធនាគារ ឬចំណាកស្រុក
- ជាមនុស្សចាស់បែកចេញពីគ្រួសារបណ្ដាលមកពីស្ថានភាពគំរាមកំហែងទទួលរងនូវអំពើហិង្សា ការរំលោភបំពានលើរាងកាយ ផ្លូវចិត្ត ឬកេងប្រវ័ញ្ចគ្រប់រូបភាព
- ជាមនុស្សចាស់ដែលរស់នៅក្នុងស្ថានភាពលំបាកបំផុត មិនអាចបំពេញតម្រូវការចាំបាច់ និងសេវាមូលដ្ឋាន ទីជម្រក ចំណីអាហារ សម្លៀកបំពាក់ និងការថែទាំសុខភាព ដោយសារកូនចៅសាច់ញាតិពុំមានលទ្ធភាពបំពេញកាតព្វកិច្ចបីបាច់ថែរក្សា
- ជាមនុស្សចាស់ដែលអ្នកថែទាំមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាព ដែលមិនអាចផ្ដល់ការថែទាំមនុស្សចាស់បានសមស្រប
- ជាមនុស្សចាស់ដែលគ្រួសារញៀនគ្រឿងស្រវឹង ប្រព្រឹត្តល្បែងស៊ីសង ប្រើប្រាស់សារធាតុញៀនផ្សេងៗ ដែលមិនអាចផ្ដល់ការថែទាំសមស្របដល់មនុស្សចាស់

ការអនុញ្ញាតឱ្យមនុស្សចាស់រស់នៅក្នុងមជ្ឈមណ្ឌលថែទាំមនុស្សចាស់របស់រដ្ឋ ជាជម្រើសចុងក្រោយ និងបណ្ដោះអាសន្ន ហើយអាចដំណើរការទៅបានបន្ទាប់ពីអស់លទ្ធភាពក្នុងការស្វែងរកកូនចៅ ឬសាច់ញាតិ កូនចិញ្ចឹម និងសហគមន៍ជួយមើលថែ។

ខ. លក្ខណមនុស្សចាស់អាចរស់នៅក្នុងមជ្ឈមណ្ឌលថែទាំមនុស្សចាស់របស់អង្គការមិនមែនរដ្ឋាភិបាល សមាគម និង ឯកជន

- មជ្ឈមណ្ឌលថែទាំមនុស្សចាស់របស់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមត្រូវកំណត់លក្ខណសម្បត្តិមនុស្សចាស់តាមលក្ខខណ្ឌក្នុងកថាខណ្ឌខាងលើ ឬ អាចកំណត់លក្ខណៈសម្បត្តិដោយឡែក ផ្អែកតាមសមត្ថភាព និងធនធាន
- មជ្ឈមណ្ឌលថែទាំមនុស្សចាស់របស់ឯកជនត្រូវកំណត់លក្ខណសម្បត្តិមនុស្សចាស់អាចរស់នៅក្នុងមជ្ឈមណ្ឌលថែទាំមនុស្សចាស់របស់ខ្លួន ផ្អែកតាមលក្ខខណ្ឌ និងលទ្ធភាពជាក់ស្ដែង។

**មាត្រា១១._**

មនុស្សចាស់ដែលកំពុងរស់នៅក្នុងមជ្ឈមណ្ឌលថែទាំ អាចត្រូវបញ្ឈប់ឱ្យរស់នៅក្នុងមជ្ឈមណ្ឌលថែទាំបាន ៖

- ជាប្រភេទមនុស្សចាស់ដែលកូនចៅឬសាច់ញាតិមានលទ្ធភាពទទួលយកគាត់ត្រឡប់ទៅរស់នៅជាមួយវិញ
- ជាប្រភេទមនុស្សចាស់ ដែលស្មគ្រចិត្តទៅរស់នៅជាមួយកូនចៅ សាច់ញាតិ កូនចិញ្ចឹមវិញ។

## ជំពូកទី៦
## ការដោះស្រាយវិវាទ

**មាត្រា១២.-**

ក្នុងករណីទទួលបានព័ត៌មានឬរបាយការណ៍ស្តីពីបាតុភាពមិនប្រក្រតីកើតមានតាមមជ្ឈមណ្ឌលថែទាំមនុស្សចាស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើអធិការកិច្ចជាបន្ទាន់ក្នុងរយៈពេលមិនលើសពី៤៨ម៉ោង ដើម្បីដោះស្រាយបាតុភាពទាំងនោះ។

ក្នុងករណីមានបណ្តឹងឬរបាយការណ៍ស្តីពីការរំលោភបំពាន អំពើហិង្សា ឬការមិនយកចិត្តទុកដាក់លើមនុស្សចាស់ដែលកំពុងរស់នៅក្នុងមជ្ឈមណ្ឌលថែទាំមនុស្សចាស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ដើម្បីបង្កើតគណៈកម្មការចម្រុះក្នុងការចាត់វិធានការតាមផ្លូវច្បាប់។

**មាត្រា១៣.-**

ករណីមានការសង្ស័យអំពីការរំលោភបំពានលើមនុស្សចាស់ដោយអ្នកគ្រប់គ្រងឬបុគ្គលិកក្នុងមជ្ឈមណ្ឌល នឹងមានការស៊ើបអង្កេតពីសមត្ថកិច្ច ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវព្យួរការងារជនបង្ក ជាបណ្តោះអាសន្ន មិនឱ្យពាក់ព័ន្ធជាមួយនឹងមនុស្សចាស់ដោយផ្ទាល់។ រាល់ការដកហូតមនុស្សចាស់ចេញពីការថែទាំត្រូវសម្រេចធ្វើឡើងដោយតម្កល់ឧត្តមប្រយោជន៍របស់មនុស្សចាស់។

## ជំពូកទី៧
## ទណ្ឌកម្ម

**មាត្រា១៤.-**

មជ្ឈមណ្ឌលថែទាំមនុស្សចាស់ដែលរកឃើញថា មិនអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ផ្អាកសកម្មភាពជាបណ្តោះអាសន្ន
- ដកហូតលិខិតអនុញ្ញាតជាស្ថាពរ។

ទណ្ឌកម្មខាងលើនេះ មិនរាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតឡើយ។

**មាត្រា១៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតឬដំណើរការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់ដែលគ្មានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាមុន ត្រូវចាត់ទុកជាមជ្ឈមណ្ឌលលួចលាក់ និងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា១៦.-**

គ្រប់មជ្ឈមណ្ឌលថែទាំមនុស្សចាស់ដែលដំណើរការមុនអនុក្រឹត្យនេះចូលជាធរមាន ហើយមិនទាន់មានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវមកសុំការអនុញ្ញាតក្នុងរយៈពេលយ៉ាងយូរ (៦)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៩៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសរុបចំនួន ១ ៣២៨ ០០០ ០០០ រៀល (មួយប៊ីលានបីរយម្ភៃប្រាំបីលានរៀលគត់) ដោយផ្ទេរពីជំពូក ៦១ (សេវាកម្ម) ចំនួន ១ ២៩៣ ០០០ ០០០ រៀល (មួយប៊ីលានពីរយ-កៅសិបបីលានរៀលគត់ ) និងផ្ទេរពីជំពូក ៦៥ (ឧបត្ថម្ភកធន) ចំនួន ៣៥ ០០០ ០០០ រៀល (សាមសិបប្រាំលានរៀលគត់)មក ជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បើកប្រាក់រង្វាន់មេដាយជ័យលាភី និងទូទាត់ប្រាក់ចំណាយផ្សេងៗ ជូនកីឡាករ កីឡាការិនី និងគ្រូបង្វឹកដែលទទួលបានជោគជ័យ ក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី ២៩ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ដែលបានប្រព្រឹត្តទៅ កាលពីថ្ងៃទី ១៩ ដល់ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៧ កន្លងទៅនេះ ជូនក្រសួងអប់រំ យុវជន និងកីឡា (ផ្នែកយុវជន និងកីឡា )។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៩៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល។

### សម្រេច

**មាត្រា១.**-ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ក្នុងជំពូក ២១ (គម្រោងវិនិយោគផ្ទាល់)លើកទី២ សរុបចំនួន ៨០ ១០០ លានរៀល ពីខ្ទង់ឥណទានថវិកាមិនទាន់បែងចែកអចលកម្មរួបី ជូនក្រសួងចំនួន បួន ដូចខាងក្រោម÷

-ក្រសួងអប់រំ យុវជន និងកីឡា ចំនួន ២ ៨០០ លានរៀល
-ក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ២០ ០០០ លានរៀល
-ក្រសួងសាធារណការនិងដឹកជញ្ជូន ចំនួន ៤៩ ០០០ លានរៀល
-ក្រសួងធនធានទឹកនិងឧតុនិយម ចំនួន ៨ ៣០០ លានរៀល។

**មាត្រា២.-** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤០០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាង «ភ្នំនាងកង្ រី-ភ្នំទូកមាស»

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាង «ភ្នំនាងកង្រី-ភ្នំទូកមាស» ដែលមានផ្ទៃដីសរុប ចំនួន ៥០៦៣ (ប្រាំពាន់ហុកសិបបី) ហិកតា ស្ថិតក្នុងភូមិសាស្ត្រឃុំត្រងិល ឃុំពោធិ៍ ឃុំច្រណូក ឃុំដារ និងឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដូចមានផែនទីជូនភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ និងមាននិយាមកាគោល (Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
| 1 | 467365 | 1364925 | 25 | 468219 | 1360751 | 49 | 469574 | 1364943 | 73 | 471817 | 1366187 |
| 2 | 467647 | 1364695 | 26 | 467741 | 1360972 | 50 | 474341 | 1372386 | 74 | 470876 | 1365646 |
| 3 | 467730 | 1364565 | 27 | 467755 | 1361113 | 51 | 475083 | 1372150 | 75 | 470202 | 1366395 |
| 4 | 467811 | 1364231 | 28 | 467474 | 1361305 | 52 | 475771 | 1371434 | 76 | 469802 | 1367124 |
| 5 | 467924 | 1364181 | 29 | 467487 | 1361862 | 53 | 475707 | 1369773 | 77 | 469782 | 1367870 |
| 6 | 467939 | 1363888 | 30 | 467392 | 1361853 | 54 | 476142 | 1368896 | 78 | 470015 | 1368449 |
| 7 | 468152 | 1364028 | 31 | 467460 | 1362374 | 55 | 476614 | 1368798 | 79 | 470547 | 1368916 |
| 8 | 468265 | 1364263 | 32 | 467742 | 1362848 | 56 | 477263 | 1369455 | 80 | 470802 | 1369524 |
| 9 | 468415 | 1364295 | 33 | 467978 | 1363057 | 57 | 478184 | 1368443 | 81 | 471573 | 1369063 |
| 10 | 468931 | 1364621 | 34 | 467914 | 1363219 | 58 | 477668 | 1367961 | 82 | 472173 | 1370404 |
| 11 | 469069 | 1364641 | 35 | 467629 | 1363508 | 59 | 476592 | 1366150 | 83 | 473142 | 1371296 |
| 12 | 469314 | 1364383 | 36 | 467629 | 1363628 | 60 | 477052 | 1365550 | 84 | 469761 | 1370317 |
| 13 | 469581 | 1364205 | 37 | 467424 | 1363755 | 61 | 477462 | 1365654 | 85 | 469886 | 1369772 |
| 14 | 469652 | 1363925 | 38 | 467299 | 1364168 | 62 | 477732 | 1365130 | 86 | 468843 | 1369896 |
| 15 | 469585 | 1363665 | 39 | 467323 | 1364771 | 63 | 476454 | 1364172 | 87 | 468884 | 1370238 |
| 16 | 469392 | 1363268 | 40 | 468788 | 1365719 | 64 | 475917 | 1365413 | 88 | 478002 | 1372562 |
| 17 | 469473 | 1362732 | 41 | 468962 | 1365324 | 65 | 475064 | 1366960 | 89 | 478112 | 1371985 |
| 18 | 469789 | 1362066 | 42 | 468878 | 1365205 | 66 | 474759 | 1366812 | 90 | 477651 | 1371641 |
| 19 | 469751 | 1361065 | 43 | 468687 | 1365258 | 67 | 474907 | 1364261 | 91 | 477463 | 1372012 |
| 20 | 469857 | 1360903 | 44 | 468679 | 1365541 | 68 | 474507 | 1363129 | 92 | 478337 | 1371346 |
| 21 | 469533 | 1360793 | 45 | 469612 | 1365183 | 69 | 473927 | 1363115 | 93 | 478882 | 1371615 |
| 22 | 469195 | 1360595 | 46 | 469946 | 1365207 | 70 | 473497 | 1363718 | 94 | 479369 | 1370642 |
| 23 | 468779 | 1360565 | 47 | 470086 | 1364691 | 71 | 472451 | 1363544 | 95 | 478562 | 1370756 |
| 24 | 468402 | 1360578 | 48 | 469840 | 1364546 | 72 | 472153 | 1365560 | | | |

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ដើម្បីធានាឱ្យមានការថែទាំទីជម្រក និងស្ថិរភាព នៃប្រព័ន្ធអេកូឡូស៊ី សារព័នមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ សម្រាប់យូរអង្វែង
- រក្សាលំនឹងបរិស្ថាន ការពារនិងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- លើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាអ្នកពាក់ព័ន្ធក្នុងការថែរក្សា ការពារ អភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព
- បង្កើនតួនាទីប្រព័ន្ធអេកូឡូស៊ីតំបន់ការពារធម្មជាតិ សម្រាប់ជាផលប្រយោជន៍ដល់សង្គម

ជាតិគ្រប់ជំនាន់

- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។

**មាត្រា៣ .-**

ផ្ទៃដីនៃអនុក្រឹត្យតំបន់ប្រើប្រាស់ច្រើនយ៉ាង«ភ្នំនាងកង្រី-ភ្នំទូកមាស»នេះ មិនរួមបញ្ចូលដីកម្មសិទ្ធិឯកជន និងដីប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

**មាត្រា៤ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រង តំបន់ប្រើប្រាស់ច្រើនយ៉ាង«ភ្នំនាងកង្រី-ភ្នំទូកមាស» ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្ត និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ច ដើម្បីជានាកិច្ចគាំពារបរិស្ថាន ការអភិរក្សប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី តំបន់ប្រើប្រាស់ច្រើនយ៉ាង «ភ្នំនាងកង្រី-ភ្នំទូកមាស» ស្ថិតក្នុងខេត្តកំពង់ឆ្នាំង

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២០០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧




## និយាមការតារាង

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 467365 | 1364925 | 49 | 469574 | 1364943 |
| 2 | 467647 | 1364685 | 50 | 474341 | 1372386 |
| 3 | 467730 | 1364565 | 51 | 475083 | 1372150 |
| 4 | 467811 | 1364231 | 52 | 475771 | 1371434 |
| 5 | 467924 | 1364181 | 53 | 475707 | 1369773 |
| 6 | 467939 | 1363888 | 54 | 476142 | 1368896 |
| 7 | 468152 | 1364028 | 55 | 476614 | 1368798 |
| 8 | 468265 | 1364263 | 56 | 477263 | 1369455 |
| 9 | 468415 | 1364295 | 57 | 478184 | 1368443 |
| 10 | 468931 | 1364621 | 58 | 477668 | 1367961 |
| 11 | 469069 | 1364641 | 59 | 476592 | 1366150 |
| 12 | 469314 | 1364383 | 60 | 477052 | 1365550 |
| 13 | 469581 | 1364205 | 61 | 477462 | 1365654 |
| 14 | 469652 | 1363925 | 62 | 477732 | 1365130 |
| 15 | 469585 | 1363665 | 63 | 476454 | 1364172 |
| 16 | 469392 | 1363268 | 64 | 475917 | 1365413 |
| 17 | 469473 | 1362732 | 65 | 475064 | 1366960 |
| 18 | 469789 | 1362066 | 66 | 474759 | 1366812 |
| 19 | 469751 | 1361065 | 67 | 474907 | 1364261 |
| 20 | 469857 | 1360903 | 68 | 474507 | 1363129 |
| 21 | 469533 | 1360793 | 69 | 473927 | 1363115 |
| 22 | 469195 | 1360595 | 70 | 473497 | 1363718 |
| 23 | 468779 | 1360565 | 71 | 472451 | 1363544 |
| 24 | 468407 | 1360578 | 72 | 472153 | 1365560 |
| 25 | 468219 | 1360751 | 73 | 471817 | 1366187 |
| 26 | 467741 | 1360972 | 74 | 470876 | 1365646 |
| 27 | 467755 | 1361113 | 75 | 470202 | 1366395 |
| 28 | 467474 | 1361305 | 76 | 469802 | 1367124 |
| 29 | 467487 | 1361862 | 77 | 469782 | 1367870 |
| 30 | 467392 | 1361853 | 78 | 470015 | 1368449 |
| 31 | 467460 | 1362374 | 79 | 470547 | 1368916 |
| 32 | 467742 | 1362848 | 80 | 470802 | 1369524 |
| 33 | 467978 | 1363057 | 81 | 471573 | 1369063 |
| 34 | 467914 | 1363219 | 82 | 472173 | 1370404 |
| 35 | 467629 | 1363508 | 83 | 473142 | 1371296 |
